




# ពង្រឹងសមត្ថភាពក្នុងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ក្នុងវិស័យកសិកម្មនៅប្រទេសកម្ពុជា

## ប្រវត្តិដើម

គ្រោះមហន្តរាយធម្មជាតិ តែងតែបង្កផលប៉ះពាល់មកលើផលិតកម្មកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជា។ ទឹកជំនន់ ដូចជាជំនន់ឆ្នាំ២០១១ និងគ្រោះរាំងស្ងួត បង្កការខូចបង់យ៉ាងច្រើនចំពោះកសិកម្ម។ មុខសញ្ញាគ្រោះមហន្តរាយដទៃទៀត ដែលបង្កការខូចខាតធ្ងន់ធ្ងរចំពោះកសិកម្មផងដែរគឺ សត្វចង្រៃ និងជំងឺព្យុះ ដូចជាព្យុះកេតសាណានៅឆ្នាំ២០០៩។ កសិករតូចតាចដែលរស់នៅក្នុងតំបន់ងាយរងការប៉ះពាល់ពីមុខសញ្ញាគ្រោះមហន្តរាយ និងពុំមានបណ្តាញសុវត្ថិភាព ឬមធ្យោបាយជំនួសសម្រាប់ការគាំទ្រ គឺជាសហគមន៍ដែលងាយរងគ្រោះបំផុតចំពោះមុខគ្រោះមហន្តរាយនានា។ ការរងឥទ្ធិពលពីមុខសញ្ញាគ្រោះមហន្តរាយធម្មជាតិនានា បង្កឲ្យមានការប៉ះទង្គិចបន្ថែម ជាពិសេសមកលើប្រព័ន្ធផលិតកម្មខ្នាតតូច និងធ្វើឲ្យរបរចិញ្ចឹមជីវិតរបស់កសិករក្រីក្រកាន់តែងាយរងគ្រោះ ក្នុងពេលដែលពួកគេកំពុងរងគ្រោះរួចទៅហើយ ដោយសារតែផលិតភាពកសិកម្មដែលមានកម្រិត ផលចំណេញកម្រិតទាប និងកង្វះលទ្ធភាពក្នុងការបង្កើនប្រពលភាពនៃផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងជលផល។ ដោយសារមានឱកាសតិចតួចប៉ុណ្ណោះ សម្រាប់ការបង្កើនមុខរបរនៅក្រៅកសិដ្ឋាន ការខូចខាតជាបន្ថែម បង្កដោយគ្រោះមហន្តរាយមកលើសេដ្ឋកិច្ចគ្រួសាររបស់កសិករក្រីក្រ អាចមានទំហំធំធេងណាស់។



ការប្រែប្រួលអាកាសធាតុបង្កើតឲ្យមានហានិភ័យ និងភាពមិនប្រាកដប្រជាបន្ថែមទៀត ដែលបង្កើនផលប៉ះពាល់អវិជ្ជមានមកលើវិស័យកសិកម្ម និងវិស័យដែលពាក់ព័ន្ធនានា។

នៅឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតរចនាសម្ព័ន្ធស្ថាប័ន និងគោលនយោបាយ ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) គឺជាស្ថាប័នដែលផ្តល់ការសម្របសម្រួលជារួម។ គណៈកម្មាធិការនេះ ជម្រុញការធ្វើសមាហរណកម្មវិធានការកាត់បន្ថយហានិភ័យនៅមុនពេលមានគ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះអាសន្ននានានៅក្រោយគ្រោះមហន្តរាយ។ ក្រសួងសំខាន់ៗទាំងអស់ក៏ចូលរួមពាក់ព័ន្ធផងដែរ ដែលរួមទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ។

ស្របជាមួយផែនការរបស់គ.ជ.គ.ម ដើម្បីកសាងយុទ្ធសាស្ត្រសកម្មភាពរួមសម្រាប់ការកាត់បន្ថយហានិភ័យ ដែលរួមទាំងសម្រាប់វិស័យកសិកម្ម អគ្គនាយកដ្ឋានកសិកម្ម (អ.ន.ក) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសុំឲ្យមានគម្រោងរួមគ្នាមួយជាមួយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ(ហ្វាវ) ដើម្បីជួយកសាងផែនការ និងសាកល្បងវិធានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដែលជាក់លាក់ឆ្លើយតបទៅនឹងតម្រូវការក្នុងវិស័យកសិកម្ម។ អ.ន.ក បានជ្រើសរើស ស្រុកឱរ៉ាល់ ស្រុកបសេដ្ឋ ស្រុកគងពិសី និងស្រុកភ្នំស្រួចនៃខេត្តកំពង់ស្ពឺ ជាតំបន់គោលដៅសម្រាប់សកម្មភាពនៅតាមមូលដ្ឋាន។ ស្រុកទាំងនេះងាយរងគ្រោះ ដោយសារគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់។ គម្រោងនេះនឹងស្រង់យកមេរៀនសំខាន់ៗ និងយោបល់សម្រាប់កសាងផែនការ ស្តីពីវិធានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម ដើម្បីពង្រីកការអនុវត្តបន្ថែមនៅក្នុងខេត្តផ្សេងៗទៀត។

## ហ្វាវគាំទ្រឲ្យមានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម

ការគ្រប់គ្រងគ្រោះហានិភ័យនៃមហន្តរាយ គឺជាអាទិភាពរួមរបស់អង្គការហ្វាវ ដូចមានចែងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់អង្គការនេះសម្រាប់ឆ្នាំ២០១០-២០១៩។ គោលដៅយុទ្ធសាស្ត្រថ្មីនៃអង្គការហ្វាវ (ឆ្នាំ ២០១៣) ក្រោមចំណងជើងថា "បង្កើនភាពធន់នៃរបរចិញ្ចឹមជីវិតទៅនឹងការគម្រាមកំហែង និងវិបត្តិនានា" ជម្រុញបន្ថែមនូវការប្តេជ្ញារបស់អង្គការនេះ ក្នុងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការបង្កើតភាពធន់សម្រាប់

Humanitarian Aid
and Civil Protection

*តារាង ១. ប្រតិទិនអំពីមុខសញ្ញាគ្រោះថ្នាក់សម្រាប់ខេត្តកំពង់ស្ពឺ*

| មុខសញ្ញាគ្រោះថ្នាក់ | ដើមរដូវវស្សា | | | | កណ្ដាលរដូវវស្សា | | | | | រដូវប្រាំង | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ម | ម | ឧ | ម | ក | ស | ក | ត | វ | ធ | ម | ក |
| រាំងស្ងួត | | | | ■ | ■ | | | ■ | ■ | ■ | ■ | ■ |
| ទឹកជំនន់ | | | | | | | ■ | ■ | ■ | | | |
| ព្យុះ (ខ្យល់ខ្លាំង) | | | | ■ | ■ | ■ | | | | | | |
| សត្វល្អិតចង្រៃ | | | | | | | ■ | ■ | | | | |
| ជម្ងឺសត្វ | | | | | | | ■ | ■ | | | | |
| សីតុណ្ហភាពខ្ពស់ | ■ | ■ | ■ | ■ | ■ | | | | | | | |

ទប់ទល់នឹងការគម្រាមកំហែង និងវិបត្តិនានាដែលមានឥទ្ធិពលមកលើកសិកម្ម និងសន្តិសុខស្បៀង។ នៅក្នុងការរៀបចំសម្រាប់គម្រោងសាកល្បងខាងលើនៅកម្ពុជា អង្គការហ្វាវបានធ្វើការសិក្សាស៊ីជម្រៅមួយ ដើម្បីប៉ាន់ប្រមាណសមត្ថភាពស្ថាប័នសម្រាប់សម្របសម្រួលការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងអនុវត្តវិធានការនៅក្នុងវិស័យកសិកម្ម ព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ជាក់លាក់សម្រាប់កសិកម្ម និងប្រព័ន្ធផ្តល់ព័ត៌មានជាមុន ចំណេះដឹង និងបទពិសោធន៍ និងបច្ចេកវិទ្យាកាត់បន្ថយហានិភ័យក្នុងចំណោមកសិករ និងសមត្ថភាពសម្រាប់ត្រៀមបង្ការហានិភ័យការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ វិធានការឆ្លើយតប និងការស្តារឡើងវិញក្នុងវិស័យកសិកម្ម។

អគ្គនាយកដ្ឋានជំនួយមនុស្សធម៌ និងគាំពារជនស៊ីវិលនៃសហគមន៍អឺរ៉ុបផ្តល់ការគាំទ្រជាហិរញ្ញវត្ថុចំនួន ៣៧១.០០០ ដុល្លាអាមេរិកដល់សំណើគម្រោងនេះ តាមរយៈកម្មវិធីឌីពេកូ (DIPECHO) របស់ខ្លួន។ គម្រោងនេះបានចាប់ផ្តើមក្នុងខែកក្កដា ឆ្នាំ២០១២ និងត្រូវអនុវត្តរយៈពេល១៨ខែ។ នៅថ្នាក់ជាតិ អ.ន.កដឹកនាំការអនុវត្ត ក្រោមកិច្ចសហការជាមួយនាយកដ្ឋានឧតុនិយម។

## គោលដៅគម្រោង

គោលដៅចំបងនៃគម្រោងនេះគឺ ពង្រឹងភាពធន់នៃរបរចិញ្ចឹមជីវិតរបស់កសិករតូចតាច និងអ្នកនេសាទជាលក្ខណៈគ្រួសារ នៅក្នុងតំបន់ងាយរងគ្រោះ តាមរយៈកំណែលម្អការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម។ គម្រោងនេះជម្រុញការបង្កើតឧបករណ៍កសាងផែនការ និងសមត្ថភាពរឹងមាំជាងមុន សម្រាប់ការផ្តល់សេវា ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយដែលរួមទាំងបង្កើនការផ្សព្វផ្សាយដល់កសិករនៅតាមតំបន់គោលដៅក្នុងតំបន់ដែលងាយរងគ្រោះ។

កសិករប្រមាណ ១.៥០០គ្រួសារ និងបុគ្គលិកបច្ចេកទេសច្រើនជាង ២៥០នាក់ នឹងទទួលផលដោយផ្ទាល់ពីគម្រោងនេះ។ ការបង្កើនការយល់ដឹង និងការគាំទ្រដល់ការកសាងផែនការយុទ្ធសាស្ត្រនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត នឹងជម្រុញការសាយភាយនៃលទ្ធផលរបស់គម្រោងនេះ ទៅស្រុក និងខេត្តដទៃទៀត ដែលនឹងផ្តល់ប្រយោជន៍ដល់កសិករនៅក្រៅតំបន់គោលដៅនៃគម្រោងនេះផងដែរ។

គម្រោងមានគោលដៅសម្រេចឲ្យបាននូវលទ្ធផលដូចតទៅ៖

- គំរូជាក់លាក់នៃការកសាងផែនការសកម្មភាព សម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងកសិកម្ម ៖ ផែនការដំបូង នឹងត្រូវបានរៀបចំឡើងស្ថិតក្រោមអាណត្តិនៃសកម្មភាពរបស់អគ្គនាយកដ្ឋានកសិកម្ម។ ផែនការនៅថ្នាក់ខេត្ត នឹងត្រូវរៀបចំឡើងនៅខេត្តកំពង់ស្ពឺ។ មេរៀនដែលទទួលបានពីដំណើរការនេះ នឹងផ្តល់ជាគំរូសម្រាប់ពង្រីកទៅកន្លែងផ្សេងទៀត។
- ការផ្សព្វផ្សាយអំពីជម្រើសនៃការអនុវត្តល្អៗសម្រាប់ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម៖ ជម្រើសនៃការអនុវត្តល្អៗ នឹងជម្រុញនៅក្នុងឃុំមួយចំនួននៃខេត្តកំពង់ស្ពឺ តាមរយៈការិយាល័យផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា។ កិច្ចការនេះនឹងរាប់បញ្ចូលការប្រើប្រាស់ធនធានទឹកបានប្រសើរជាងមុនសម្រាប់ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ ធនាគារស្រូវដែលមានស្រាប់ចំនួនដប់ នឹងទទួលបានការឧបត្ថម្ភ តាមរយៈការបណ្តុះបណ្តាលអំពីការគ្រប់គ្រង និងពូជស្រូវ ដែលធន់នឹងគ្រោះរាំងស្ងួត។
- ការអភិវឌ្ឍសមត្ថភាពលើព័ត៌មាន ស្តីពីអាកាសធាតុ និងឧតុនិយមជាក់លាក់សម្រាប់វិស័យកសិកម្ម៖ កិច្ចការនេះរាប់បញ្ចូលការសាកល្បងរៀបចំព្រឹត្តិបត្រព័ត៌មាន អំពីអាកាសធាតុទៅតាមរដូវកាលសម្រាប់វិស័យកសិកម្ម។



## ដៃគូអនុវត្ត

ស្ថាប័ននៅថ្នាក់ជាតិដែលពាក់ព័ន្ធនៅក្នុងការសម្របសម្រួល និងការអនុវត្តគម្រោងនេះមានជាអាទិ៍៖ អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

នៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ក្នុងខេត្តកំពង់ស្ពឺ ដៃគូនានារួមមាន មន្ទីរកសិកម្មខេត្ត មន្ទីរធនធានទឹក និងឧតុនិយមខេត្ត អង្គការស្រែខ្មែរ និងអង្គការជំនួយសំរាប់ការអភិវឌ្ឍន៍ហ្សូម្ប៉ា ក៏ដូចជា គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តផងដែរ។